**គោរពជូន**

**ឯកឧត្តម ប្រធាននិយ័តករទូរគមនាគមន៍កម្ពុជា**

**កម្មវត្ថុ** : សំណើសុំជួយជំរុញឲ្យមានសកម្មភាពផ្សព្វផ្សាយខ្លឹមសារអបរំ តាមរយៈសម្លេង(Calltune) និងសារ(SMS) នៅគ្រប់បណ្តាក្រុមហ៊ុនផ្តល់សេវាកម្មទូរស័ព្ទចល័ត ដើម្បីអបអរសាទរទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស លើកទី៧ ឆ្នាំ២០២៣។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម ប្រធាននិយ័តករទូរគមនាគមន៍កម្ពុជា** ជ្រាបថា៖ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នឹងរៀបចំទិវាជាតិអន្តរសាសនា លើកទី៧ ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅព្រឹក ថ្ងៃអាទិត្យ ទី២០ ខែសីហា ឆ្នាំ២០២៣។ ហេតុនេះ ខ្ញុំសូមស្នើសុំ **ឯកឧត្តម** ពិនិត្យលទ្ធភាព និងជួយសម្របសម្រួលក្នុងការជំរុញទៅគ្រប់បណ្តាក្រុមហ៊ុនផ្តល់សេវាកម្មទូរស័ព្ទចល័ត ក្នុងការផ្សព្វផ្សាយខ្លឹមសារអបរំ តាមរយៈសម្លេង(Calltune) និងសារ(SMS) ឲ្យបានដល់ប្រជាពលរដ្ឋ ដែលមានកាលបរិច្ឆេទ និងខ្លឹមសារ ដូចខាងក្រោម៖

១. <u>សម្លេង(Calltune)៖</u>

- កាលបរិច្ឆេទ: **ចាប់ពី ម៉ោង២៤:00យប់ ថ្ងៃទី១៣ ខែសីហា រហូតដល់ ម៉ោង២៤:00យប់ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៣។**
- ខ្លឹមសារ : **«ថ្ងៃទី២០ ខែសីហា ជាទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស! យើងទាំងអស់គ្នាត្រូវចូលរួមប្រឆាំងការជួញដូរមនុស្សគ្រប់ទម្រង់ ដើម្បីសុវត្ថិភាពរបស់យើង!»**

២. <u>សារ(SMS)៖</u>

- កាលបរិច្ឆេទ: **ព្រឹក ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៣។**
- ខ្លឹមសារ : **«ទោះបីជាសាសនិកសាសនាណាក៏អាចក្លាយជាជនរងគ្រោះដោយអំពើជួញដូរមនុស្សបាន សូមកុំធ្វេសប្រហែស!»**

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម ប្រធាននិយ័តករទូរគមនាគមន៍កម្ពុជា** ពិនិត្យលទ្ធភាព និងសម្រេចតាមការស្នើសុំដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ។

ថ្ងៃ............................ ខែ....................ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី............ខែ.............ឆ្នាំ២០២៣

**អគ្គលេខាធិការ**